ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៤០

ចុះថ្ងៃទី០៨ ០៧ ២០០២

សាលដីកា

លេខ : ០៥

ចុះថ្ងៃទី១២ ០២ ២០០៣

# តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី១២ខែកុម្ភៈឆ្នាំ២០០៣ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

| | | | |
|---|---|---|---|
| ១ - ឯកឧត្តម | ឃឹម | ប៉ុណ្ណ | ប្រធាន |
| ២ - លោក | ឈឹម | ស៊ីផល | ចៅក្រម |
| ៣ - លោក | គង់ | ភីរុណ | ចៅក្រម |
| ៤ - លោក | ប្រាក់ | គឹមសាន | ចៅក្រមរបាយការណ៍ |
| ៥ - លោក | ស៊ីវ | គេង | ចៅក្រម |
| លោក | ផោង | ស្រ៊ុន | ក្រឡាបញ្ជី |
| តំណាងមហាអយ្យការ | | | |
| លោក | ឈួន | ចាន់ថា | ព្រះរាជអាជ្ញា |

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ ៣១២ ចុះថ្ងៃទី២៦ ១០ ២០០១ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ៤០ ចុះថ្ងៃទី០៨ ០៧ ២០០២ របស់តុលាការកំពូល ។

- ជនជាប់ចោទឈ្មោះ អ៊ី សំអឿន "ចុងបណ្តឹងសាទុក្ខ" ភេទ ប្រុស អាយុ ១៧ ឆ្នាំ ជាតិខ្មែរ របររកស៊ី សិស្ស ទីលំនៅសព្វថ្ងៃផ្ទះលេខ២៨៥អឺ៣ ផ្លូវលេខ១១០ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ឪពុកឈ្មោះខែក ផល្លា ម្តាយឈ្មោះពៅ ជា នៅលីវ ។ ក្នុងឃុំ ។

- ត្រូវចោទពីបទ មនុស្សឃាតគិតទុកជាមុន និងប្លន់ ប្រព្រឹត្តនៅក្រុងភ្នំពេញកាលពីថ្ងៃទី០៩ ៦ ១៩៩៨ តាមមាត្រា ៣១ -៣៤ និងមាត្រា៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- មេធាវី លោក ឡាយ ស្រ៊ីវ

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះខែក សុវណ្ណ "ម្ចាស់បណ្តឹងសាទុក្ខ" ភេទ ប្រុស អាយុ ៣៨ ឆ្នាំ ជាតិខ្មែរ ត្រូវជាប្តីជនរងគ្រោះ របររកស៊ី បុគ្គលិកនាយកដ្ឋានគ្រប់គ្រងរាជដំណាក់ ទីលំនៅសព្វថ្ងៃផ្ទះលេខ ២៨៥អឺ០ ផ្លូវ១១០ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ប្រពន្ធឈ្មោះចន អៀងលី មានកូន ៣នាក់ ឪពុកឈ្មោះខែក ស៊ី ម្តាយឈ្មោះភួង សិណ ។

- មេធាវី គ្មាន

- តាមរឿងហេតុកាលពីថ្ងៃទី០៩ ៦ ១៩៩៨ វេលាម៉ោង១៣ ,០០ ជនរងគ្រោះ

ទី១ ឈ្មោះ ចន សៀងលី កំពុងដេកមើលទូរទស្សន៍នៅក្នុងផ្ទះជនរងគ្រោះទី២ ឈ្មោះ ស៊ឹម វេត កំពុងដេកនៅលើឡៅតឿ ។ ពេលនោះជនល្មើសឈ្មោះ អ៊ី សំអឿន បានធ្វើសកម្មភាពដោយឡើងតាមជញ្ជាំងផ្ទះ ហើយកាច់ចំរឹងបង្អួចចូលទៅក្នុងផ្ទះលេខ១២៨៩អ៊ី០ ដោយមានកាន់កូនកាំបិតចុងស្រួចមួយ ជនរងគ្រោះទី១ បានសួរជនល្មើសថា ឯងចូលមកផ្ទះអញលួចអី ចាំមើលអញប្រាប់ឪពុក ម្តាយរបស់ឯង ដោយទឹងពីថ្ងៃមុនផង ក៏មានប្រតាយប្រតប់គ្នា ពេលនោះជនល្មើសបានស្ទុះទៅយកកូនកាំបិតទៅចាក់លើជនរងគ្រោះ ទី១ ជាច្រើនកាំបិត បណ្តាលឲ្យដាច់ខ្យល់ស្លាប់នៅនឹងកន្លែង បន្ទាប់មកជនល្មើសបានចាប់ជនរងគ្រោះទី២ចងមាត់ ហើយចាក់មួយកាំបិតចំបំពង់ក បណ្តាលឲ្យសន្លប់បាត់ស្មារតី រួចជនល្មើសចូលទៅក្នុងបន្ទប់ទឹកលាងដៃ ។ បន្ទាប់មកក៏បានចាក់សោរយកលុយបាន៣.០០០ រៀល ហើយចេញទៅក្រៅទៅយូឌូបជិះទៅច្បាររំពៅ ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមតុលាការក្រុងភ្នំពេញថា: សំរេចចោទប្រកាន់លើឈ្មោះ អ៊ី សំអឿន ពីបទ:មនុស្សឃាតគិតទុកជាមុននិងប្លន់ ប្រព្រឹត្តនៅក្រុងភ្នំពេញកាលពីថ្ងៃទី០៩-៦-១៩៩៨ តាមមាត្រា ៣១ .៣៤និងមាត្រា២៨នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ០១ក"ចុះថ្ងៃទី១៣-០១-១៩៩៩ របស់តុលាការក្រុងភ្នំពេញដែលមានសេចក្តីសំរេចដូចតទៅ :

១- ផ្តន្ទាទោសឈ្មោះ អ៊ី សំអឿន ដាក់ពន្ធនាគារចំនួន២០ ឆ្នាំ ១ខែ គិតចាប់ពីថ្ងៃឃុំខ្លួន "ថ្ងៃឃុំខ្លួនថ្ងៃទី១៦-៦-៩៨"ពីបទមនុស្សឃាតគិតទុកជាមុននិងប្លន់ ប្រព្រឹត្តនៅក្នុងភ្នំពេញកាលពីថ្ងៃទី០៩-៦-៩៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រាទី៣១និង៣៤ និងមាត្រាទី២៨នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២- សាលក្រមនេះ ប្រកាសជាសាធារណៈនៅចំពោះមុខគូក្តីបើកផ្លូវឧទ្ធរណ៍រយៈពេល ២ ខែ គិតចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ០៤"ក"ចុះថ្ងៃទី១២-០២ ១៩៩៩របស់ឈ្មោះ ខែក សុវណ្ណ ប្តឹងតវ៉ាពីសាលក្រមព្រហ្មទណ្ឌលេខ០១"ក"ចុះថ្ងៃទី១៣-០១ ១៩៩៩ របស់តុលាការក្រុងភ្នំពេញ លើចំណុចទី១ "ផ្តន្ទាទោស "នៃសេចក្តីសំរេច ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា: សុំតំកល់សាលក្រមលេខ០១"ក"ចុះថ្ងៃទី១៣-០១-៩៩ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ០៣១២ចុះថ្ងៃទី២៦-១០-២០០១ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១២-០២-១៩៩៩ របស់ឈ្មោះ ខែក សុវណ្ណ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាល់នឹងគតិច្បាប់ ។

២- តំកល់សាលក្រមព្រហ្មទណ្ឌលេខ០១"ក"ចុះថ្ងៃទី១៣-០១-១៩៩៩របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ដោយគ្រាន់លុបមាត្រាទី៣៤នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលក្នុងចំណុចទី១ នៃសេចក្តីសំរេចចោល ។ ចំណុចក្រៅពីនេះរក្សាទុកជាបានការដដែល ។

...../.....

៣ - សាលដីកានេះជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទមេធាវីការពារជនជាប់ចោទនិង ដើមបណ្តឹងរដ្ឋប្បវេណីបើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

- បានឃើញបណ្តឹងសាទុក្ខលេខ ៩២ ចុះថ្ងៃទី២៦ .១២ - ២០០១ របស់ឈ្មោះ ខែក សុវណ្ណ ប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ១៣១២ ចុះថ្ងៃទី២៦ .១០ - ២០០១ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញលិខិតបង្គាប់ឱ្យធ្វើសារណារបស់ ខែក សុវណ្ណ ដែលបានទទួលធ្វើរួចកំណត់ច្បាប់ .

- បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍ .

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការ កំពូលថា: មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះអ៊ី សំអឿន ពីបទមនុស្សឃាតគិតទុកជាមុននិងប្លន់ប្រព្រឹត្តនៅក្រុងភ្នំពេញកាលពីថ្ងៃទី០៩ - ០៦ - ១៩៩៨ តាមមាត្រា ៣១ ,៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដូច្នេះ

១ - បណ្តឹងសាទុក្ខរបស់ឈ្មោះ ខែក សុវណ្ណ ធ្វើទៀងក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យពិចារណា ។

២ - តំកល់សាលដីកាព្រហ្មទណ្ឌលេខ១៣១២ ចុះថ្ងៃទី២៦ - ១០ - ២០០១ របស់ សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

- បានស្តាប់ជនជាប់ចោទឈ្មោះអ៊ី សំអឿន អះអាងនៅពេលសវនាការថា: ... ខ្ញុំបានប្រព្រឹត្តបទល្មើសប្លន់មែន និងសូមសារភាពនូវកំហុសទាំងនោះព្រមទាំងកែប្រែខ្លួនឱ្យបានល្អជានិច្ច សូមតុលាការបន្ធូរបន្ថយទោស ។

- បានស្តាប់លោកទេព្យ ស៊ីន មេធាវីការពារឱ្យជនជាប់ចោទបានលើកឡើងនូវការសន្និដ្ឋានរបស់ខ្លួននៅពេលសវនាការថា: បើនិយាយពីអង្គច្បាប់ក្នុងរឿងនេះអាចបញ្ជាក់បានថា. ជនជាប់ចោទដែលជាអ្នកប្រព្រឹត្តបទល្មើសនោះគឺជាលើកដំបូង ហើយក៏ស្ថិតនៅក្នុងភាពអនីតិជនទៀតៗ ចំពោះតុលាការក្រុង បានសំរេចឱ្យជនជាប់ចោទតាមមាត្រា ៣៤ និង ៣១ មានរយៈពេលជាប់ពន្ធនាគារ៦ឆ្នាំកន្លះ តាមបទល្មើសពីរ ប៉ុន្តែសាលាឧទ្ធរណ៍សំរេចតាមតុលាការក្រុង ហើយលប់បទល្មើសដែលមានចែងតាមមាត្រា ៣៤ ចោល ឃើញថាមិនអាចបន្ថែមបទទណ្ឌកម្មនៃបទល្មើសផ្សេងទៀតដែរ ដូច្នេះបើជនជាប់ចោទទទួលទណ្ឌកម្មនិងទទួលកំហុស បានសារភាពចំពោះមុខច្បាប់ គប្បីបន្ធូរបន្ថយទោសឱ្យបានអតិបរិមា ដែលការសំរេចរបស់តុលាការថ្នាក់ក្រោមមិនទាន់បន្ថយទោសនៅឡើយ សូមក្រុមប្រឹក្សាតុលាការកំពូលរកយុត្តិធម៌ឱ្យជនជាប់ចោទជាអនីតិជនផង ។

- បានស្តាប់តំណាងមហាអយ្យការថា ពុំមានអ្វីបន្ថែមទៀតទេ សូមរក្សាការសន្និដ្ឋានរបស់ខ្លួនទុកនៅជាបានការដដែល ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍ .

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ .

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទនិងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ .

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ....៤....

តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៥២ ចុះថ្ងៃទី ២៦ - ១២ - ២០០១ របស់លោក ខែក សុវណ្ណ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ជនជាប់ចោទឈ្មោះ អ៊ី សំអឿន ពិតជាបានចាក់ជនរងគ្រោះឈ្មោះ ចន អៀងលី បណ្តាលអោយស្លាប់និងបានចាក់ជនរងគ្រោះទី២ឈ្មោះ ស៊ឹម វេត បណ្តាលអោយមានរបួសជាទម្ងន់ប្រាកដមែន ។

- យល់ឃើញថា ជនជាប់ចោទឈ្មោះ អ៊ី សំអឿន ជាអនីតិជន មានអាយុ១៧ ឆ្នាំ ត្រូវបានទទួលស្ថានសំរាលទោសតាមមាត្រា ៦៨ ចំណុចទី២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- យល់ឃើញថា សាលាឧទ្ធរណ៍បានសំរេចផ្តន្ទាទោសលើជនជាប់ចោទ តែពីបទធ្វើមនុស្សឃាតដោយគិតទុកជាមុនលើឈ្មោះ ចន អៀងលី ។ ប៉ុន្តែតាមអង្គហេតុនៃរឿងនេះ ជនជាប់ចោទបានចាក់សំលាប់ឈ្មោះស៊ឹម វេត ដែរ គ្រាន់តែមិនបានសំរេច ហើយព្រះរាជអាជ្ញាអមតុលាការក្រុងភ្នំពេញ ក៏ពុំទាន់បានចោទប្រកាន់ពីបទប៉ុនប៉ងធ្វើមនុស្សឃាត លើឈ្មោះ ស៊ឹម វេត ដែរ ដូច្នេះតុលាការកំពូលពុំមានសមត្ថកិច្ច កិច្ចសំរេចអំពីបទល្មើសនេះទេ ។

- យល់ឃើញថា នាពេលសវនាការនេះ លោកមេធាវីជនជាប់ចោទលើកឡើងថា . តុលាការក្រុងភ្នំពេញ បានផ្តន្ទាទោស ៦ ឆ្នាំ ៦ ខែ លើជនជាប់ចោទពីបទមនុស្សឃាតគិតទុកជាមុននិងប្លន់ តាមមាត្រា ៣១ និង ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ប៉ុន្តែសាលាឧទ្ធរណ៍បានលប់មាត្រា ៣៤ ចេញហើយ ហើយនៅតែផ្តន្ទាទោស ៦ ឆ្នាំ ៦ ខែ ដដែល ។ ការលើកបែបនេះ នេះតុលាការកំពូលពុំអាចបន្ថយទោសបានទេ ពីព្រោះមាត្រា ៣១ រួមមានទាំងមនុស្សឃាត និង ប្លន់ រួចទៅហើយ ហើយតុលាការនេះជំនុំជំរះតែលើអង្គច្បាប់ប៉ុណ្ណោះ ។

- យល់ឃើញថា លោកខែក សុវណ្ណ បានទទួលលិខិតបង្គាប់អោយធ្វើសារណានិងបានទទួលដីកាកោះហើយ ប៉ុន្តែលោកពុំបានធ្វើសារណាជូនមកតុលាការកំពូលទេ ហើយក៏ពុំបានមកចូលរួមនាសវនាការនេះដែរ ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៣១២ ចុះថ្ងៃទី ២៦ - ១០ - ២០០១ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្តឹង
រដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ

១ - ទទួលបណ្តឹងសាទុក្ខលេខ ៥៦ ចុះថ្ងៃទី ២៦ - ១២ - ២០០១ របស់ លោក

ខែក សុវណ្ណ ទុកជាត្រឹមត្រូវតាមទំនងច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនិងគតិច្បាប់ ។

២ - តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៣១២ ចុះថ្ងៃទី ២៦ - ១០ - ២០០១ របស់ សាលាឧទ្ធរណ៍ ទុកជាគ្មានការពេញទាំងមូល ។

៣ - សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៣ ។